គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY

លេខ 0241/09 គ.ស.ម

បំរើ ការពារ កសាង

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩

# សេចក្តីថ្លែងការណ៍

ឆ្នាំនេះគឺជាខួបលើកទី៦១ នៃសេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស ១០ធ្នូ១៩៤៨-១០ធ្នូ២០០៩ និងជាថ្ងៃខួបលើកទី១៨ ដែលភាគីទំនាស់ខ្មែរយល់ព្រមទទួលយកគោលការណ៍សិទ្ធិមនុស្សនេះមកផ្សព្វផ្សាយ និងអនុវត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ រយៈកាល១៨ឆ្នាំកន្លងមកនេះ គួរណាស់តែប្រជាពលរដ្ឋខ្មែរទទួលបាននូវការគោរពសិទ្ធិរបស់ខ្លួនពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច និងរាជរដ្ឋាភិបាលខ្មែរយ៉ាងត្រឹមត្រូវ និងពិតប្រាកដ ។ ប៉ុន្តែប្រជាពលរដ្ឋខ្មែរបែរជាត្រូវទទួលការគាបសង្កត់ពីសំណាក់អ្នកមានបុណ្យស័ក្តិ មាសប្រាក់ និងពីសមត្ថកិច្ចមួយចំនួនទៅវិញ ។ សិទ្ធិ ជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ដូចជា សិទ្ធិមានអាហារ សិទ្ធិមានលំនៅដ្ឋាន សិទ្ធិទទួលការថែទាំសុខភាព សិទ្ធិទទួលការសិក្សា សិទ្ធិមិនរើសអើងនយោបាយ សិទ្ធិបញ្ចេញមតិ ការរើសអើងពលរដ្ឋខ្មែរកម្ពុជាក្រោមជាដើម ។ល។ ប្រជាពលរដ្ឋត្រូវបានព្រងើយកន្តើយពីសំណាក់សមត្ថកិច្ច និងអ្នកមានអំណាច និងប្រាក់មាសជាក់ស្តែងការបណ្តេញចេញពីលំនៅដ្ឋាន នៅតំបន់ដីក្រហម បឹងកក់ រាជធានីភ្នំពេញ និងនៅខេត្តមួយចំនួន ដូចជាខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តកំពត ការផ្សឹកព្រះសង្ឃ **ទីម សាខន** ហើយបញ្ជូនទៅអោយយួនកាត់ទោស ។ល។ ធ្វើអោយ ប្រជាពលរដ្ឋរាប់រយពាន់គ្រួសារជួបប្រទះនូវការខ្វះខាតម្ហូបអាហារ ទីជម្រក ខ្វះសាលារៀន និងខ្វះការថែទាំសុខភាព ដែលពួកគាត់កំពុងតែខ្វះខាតស្រាប់ ឱ្យពួកគាត់រឹតតែជួបប្រទះនឹងសេចក្តីទុក្ខវេទនាខ្លាំងឡើងៗជាលំដាប់ហើយរស់នៅស្ទើរតែមិនមែនជាមនុស្សប្រកបដោយសេចក្តីថ្លៃថ្នូរសោះឡើយ ។ សិទ្ធិបញ្ចេញមតិរឹតតែទទួលនូវការគំរាមគំហែងខ្លាំងឡើងៗជាលំដាប់ សូម្បីតែអ្នកតំណាងរាស្ត្រដែលមានសំឡេងភាគតិចនៅរដ្ឋសភាក៏ក្រុមអ្នកមានអំណាច និងមានសំឡេងភាគច្រើនបង្កើតច្បាប់ផ្សេងៗ រារាំងមិនអោយអស់លោកអាចបំពេញតួនាទីរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញបានដែរ ។ ការប្រើតុលាការដែលពុំមានលក្ខណៈអព្យាក្រឹត្យដើម្បីបំបិទមាត់អ្នកជំទាស់ការដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រយ៉ាងងាយៗ រួមទាំងការចាប់អ្នកការសែតមួយចំនួនដាក់ពន្ធនាគារគឺជាសក្ខីកម្មបង្ហាញ ថាប្រទេសកម្ពុជាកំពុងតែរំកិលខ្លួនបន្តិចម្តងៗទៅរកលទ្ធិផ្តាច់ការដូចមុនឆ្នាំ១៩៩១ ។ ការអនុម័តច្បាប់ថវិកា ថ្មីៗនេះដែលបន្ថយចំណាយខាងសង្គមកិច្ច បញ្ជាក់ច្បាស់ថា អ្នកដឹកនាំប្រទេសពុំមានឆន្ទៈពិតប្រាកដក្នុងការកាត់បន្ថយភាពក្រីក្រ និងបំបាត់អំពើពុករលួយ ដែលរហូតមកទាល់នឹងពេលនេះហើយ នៅមិនទាន់ដឹងថាពេលណាទើបចេញរួច ។ ដោយសារតែពិនិត្យ និងតាមដានកន្លងមកគណបក្សសិទ្ធិមនុស្ស សង្កេតឃើញថា

Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 / 023 884 649 | Email: hrpcambodia@yahoo.com| Website: www.hrpcambodia.info

ឱ្យតែជិតដល់ការប្រជុំសុំជំនួយពីបរទេស  រដ្ឋាភិបាលតែងតែលើកយកច្បាប់នេះមកជន្លម្ចាស់ជំនួយ  និងសន្យាគ្រប់បែបយ៉ាង ។ ប៉ុន្តែបន្ទាប់ពីបានទទួលអំណោយពីបរទេស រដ្ឋាភិបាលតែងតែធ្វើមិនដឹងមិនឮពីបញ្ហានេះឡើយ ។ ស្ថិតនៅចំពោះមុខ សភាពការណ៍បែបនេះ គណបក្សសិទ្ធិមនុស្ស ស្នើដោយទទូចដល់ម្ចាស់ជំនួយទាំងអស់ ដែលមានបំណងមកជួយ ពលរដ្ឋខ្មែរសូមមេត្តាផ្តល់ជំនួយដោយតាមដានការអនុវត្តន៏ឱ្យបានពិតប្រាកដដូចជា :

-ត្រូវលើកកំពស់សិទ្ធិបញ្ចេញមតិ  ឱ្យបានប្រសើរឡើងដោយត្រូវធ្វើវិសោធន៏កម្មច្បាប់ដែលបានកំរិតសិទ្ធិអ្នកតំណាងរាស្ត្រ និងពលរដ្ឋនឹងបញ្ឈប់ការដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រយ៉ាងងាយៗនោះចោលចេញ ត្រូវកែប្រែប្រព័ន្ធតុលាការឱ្យមានឯករាជ្យភាពពិតប្រាកដមិនមែនឯករាជ្យតែរូបភាពដូចសព្វថ្ងៃនេះទេ

-ច្បាប់ប្រឆាំងនឹងអំពើពុករលួយត្រូវចេញឱ្យបានយ៉ាងឆាប់បំផុត  ហើយបើយ៉ាងយូរណាស់នៅត្រឹមត្រីមាសទី២ ឆ្នាំ២០១០ និងសូមអោយមានអានុភាពប្រតិសកម្មផង

-បញ្ឈប់ការដេញប្រជាពលរដ្ឋ  ដោយយកលេសអភិវឌ្ឍន៏  បែបក្លែងក្លាយបែបនេះតទៅទៀត ។ ក្នុងករណីដែលមានការប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ គឺត្រូវផ្តល់សំណងជូនពួកគាត់ជាមុនឱ្យបានសមរម្យផង

-បញ្ឈប់ការរើសអើងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមដែលបានមករស់នៅកម្ពុជា  និងគប្បីផ្តល់សិទ្ធិជូនពួកគាត់ឱ្យដូចជាពលរដ្ឋខ្មែរទូទៅដែរ

ជាថ្មីម្តងទៀត  គណបក្សសិទ្ធិមនុស្ស  ទទូចដល់ម្ចាស់ជំនួយទាំងអស់បើលោកមានបំណងជួយពលរដ្ឋខ្មែរមែន  សូមលោកតាមដានសកម្មភាពឱ្យបានម៉ត់ចត់ និងថ្កោលទោសផង ផ្ទុយពីនេះពលរដ្ឋខ្មែរ នឹងបន្តរងទុក្ខហើយជំនួយនឹងពុំបានដល់ដៃពលរដ្ឋខ្មែរដែលរងគ្រោះឡើយ ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង
លេខទូរស័ព្ទ : ០១១ ៧៧៧ ៧៥០